# ការផលិតពូជត្រីទីឡាព្យា



ត្រីទីឡាព្យា ទោះបីវាមិនសូវជាចំណូលចិត្តរបស់អ្នកបរិភោគក៏ដោយចុះ ក៏ត្រីនេះត្រូវបានគេទិញយកទៅធ្វើជាម្ហូបបរិភោគជាហូរហែរដែរ។

នៅប្រទេសកម្ពុជាយើង ការចិញ្ចឹមត្រីទីឡាព្យាសម្រាប់លក់ក្នុងទីផ្សារក្នុងរូបភាពធំដុំមិនសូវមានទេ ព្រោះគេយល់ថា ជាត្រីដែលពិបាកលក់ក្នុងទីផ្សារ ភាគច្រើនត្រីទីឡាព្យាធំៗដែលឃើញមានលក់ក្នុងទីផ្សារ គឺច្រើនត្រូវបាននាំចូលមកពីប្រទេសជិតខាងយើងប៉ុណ្ណោះ។

យើងមិនចាំបាច់ត្រូវចេះភ្ញាស់ត្រីទីឡាព្យានេះទេ ព្រោះវាជាត្រីងាយមានកូនជាទីបំផុតតាមបែបធម្មជាតិរបស់វា។ គ្មានហេតុផលអ្វីត្រូវចេះរបៀបភ្ញាស់វានោះទេ បើយើងមានត្រីមេពូជច្រើន យើងនឹងទទួលបានពងកូនច្រើនទៅតាមនោះដែរ។

## ការរៀបចំស្រះសម្រាប់យកពងកូន :



- ស្រះត្រូវមានទំហំពី ៥០០ ទៅ ១០០០ ម៉ែត្រការ៉េ ឬប្រើស្រែធ្វើជាស្រះក៏បាន តែមានការពិបាកបន្តិចនៅពេលយើងចាប់ផ្តើមប្រមូលកូនត្រី។ បើសិនមានស្រះចាស់ស្រាប់ត្រូវបូមទឹកចេញរួចកៀរសម្អាតស្រះឲ្យស្អាត ប្រើកំបោរបាចឲ្យពេញបាតស្រះ ដើម្បីសម្លាប់បាក់តេរីកុំឲ្យត្រីកើតជម្ងឺ។ ត្រូវធ្វើការងារនេះនៅដើមរដូវវស្សា គឺមុនរដូវភ្លៀងមកដល់។

- នៅដើមរដូវវស្សាពេលមានទឹកភ្លៀងមកដល់ ឬមុនរដូវមានភ្លៀងធ្លាក់ត្រូវបូមទឹកបញ្ចូលក្នុងស្រះ រួចលែងត្រីមេពូជធំៗផ្តល់ចំណីឲ្យវាឲ្យបានត្រឹមត្រូវ បន្ទាប់មកត្រូវបង្កើតឲ្យមានប្លង់គុងទុកសម្រាប់ឲ្យកូនត្រីស៊ី។

ខណៈរដូវវស្សាចូលមកដល់ មានភ្លៀងធ្លាក់ ត្រីទីឡាព្យាចាប់ផ្តើមមានពង និងកូន។ ដើម្បីការពារកូនត្រី គួរបង្កើតជាជម្រកមួយសម្រាប់ឲ្យត្រីចូលពង គឺត្រូវរៀបជាសម្រាស់នៅជ្រុងមួយនៃស្រះទុកឲ្យត្រីចូលជ្រកពង។

ត្រីមេពូជត្រូវជ្រើសរើសត្រីគ្មានរបួសគ្មានក្រមរនៅលើខ្លួន មានសុខភាពល្អ ព្រុយរបស់វានៅស្អាតគ្មានរបួសដាច់ និងត្រូវមានទម្ងន់ចាប់ពី ៣០០ ទៅ ៥០០ក្រាមឡើងទៅ អត្រាពូជមេបា គឺឈ្មោលមួយ ញីមួយ ឬឈ្មោលមួយញីពីរក៏បាន ដងស៊ីតេពូជ គឺក្នុងមួយម៉ែត្រការ៉េស្មើពីរក្បាល។ អ្នកចិញ្ចឹមត្រូវប្រើពេលយ៉ាងហោចណាស់ ១៥-២០ថ្ងៃ ដើម្បីបំប៉នមេពូជឲ្យធាត់។ ដើម្បីបំប៉នឲ្យត្រីនោះធាត់ត្រូវប្រើរូបមន្តចំណីខាងក្រោម :

## កន្ទក់ចុងអង្ករ (ចម្អិន) រួមជាមួយម្សៅត្រី ដោយប្រើរូបមន្ត

- ម្សៅត្រី ២០ ភាគរយ
- កន្ទក់ ៧៥ ភាគរយ
- ចុងអង្ករ ៥ ភាគរយ




ក្នុងមួយថ្ងៃត្រូវឲ្យត្រីស៊ីម្តងទៅពីរដង។ ចំពោះបរិមាណចំណីគឺស្មើមួយទៅពីរភាគរយនៃទម្ងន់ត្រីចិញ្ចឹម។ បើសិនជាស្ថិតក្នុងស្ថានភាពបរិយាកាសដែលមានកំដៅ ២៤ ទៅ ៣២ដឺក្រេ ក្រោយពេលចិញ្ចឹមបំប៉នបាន ១០ ទៅ ១៥ថ្ងៃ បន្ទាប់ពីបានដាក់ត្រីមេពូជចូលក្នុងស្រះ ត្រីវានឹងចាប់ផ្តើមពង។ បន្ទាប់ ១៥ ទៅ ១៧ថ្ងៃ ក្រោយពេលត្រីពងរួច យើងអាចចាប់ផ្តើមប្រមូលត្រីម្សៅ (កូនត្រី)។

## របៀបប្រមូលត្រីម្សៅ :

ប្រើសំណាញ់មានក្រឡាធំ ដើម្បីអូសចាប់យកត្រីមេពូជដាក់ទៅជ្រុងម្ខាងនៃស្រះ រួចចាប់ត្រីមេពូជនោះចេញ យកទៅដាក់នៅក្នុងស្រះមួយផ្សេង បំប៉នវាឲ្យធាត់ ដើម្បីឲ្យវាពងក្នុងវគ្គថ្មីទៀត។

ប្រើប្រាស់ស្រះដែលមានកូនត្រីក្នុងនោះស្រាប់ ដើម្បីផ្សាំត្រីម្សៅឲ្យធំ។ វិធីមួយទៀតនោះ គឺយើងប្រើកន្ទ្រងសំណាញ់ក្រឡាញឹក ដើម្បីដួសត្រងយកកូនត្រីម្សៅចេញ ទៅដាក់នៅក្នុងស្រះផ្សេងសម្រាប់ចិញ្ចឹម។

ទោះដងកូនត្រីម្សៅចេញ ឬចាប់យកត្រីមេបាចេញក៏ដោយ វាសឹងមានផលវិបាកដូចគ្នា ដោយសារបញ្ហានេះអ្នកចិញ្ចឹមត្រីខ្លះបានបែកគំនិតប្រើអាងស៊ីម៉ង់ លូ អណ្តូង ឬកាធុនធំៗ សម្រាប់ដាក់ត្រីមេពូជឲ្យពង ព្រោះការប្រើវិធីនេះងាយស្រួលឲ្យគេចាប់យកត្រីមេពូជចេញទៅដាក់នៅក្នុងកន្លែងផ្សេង រួចប្រមូលយកកូនត្រីទៅដាក់នៅក្នុងស្រះផ្សេងដែរ។



នៅមានវិធីមួយទៀត ដែលត្រូវបានគេធ្វើដែរនោះ គឺការដាក់ពូជមេត្រីទៅក្នុងស្បៃ ដែលរៀបចំដាក់ក្នុងបៃរួចជាស្រេចហើយនោះ ធ្វើបែបនេះ គេអាចគ្រប់គ្រងទៅលើការប្រមូលយកកូនបានងាយជាង ហើយក៏អាចប្រើប្រាស់ទីកន្លែងដែលកូនត្រីម្សៅញាស់នោះធ្វើជាកន្លែងចិញ្ចឹមផ្សាំវាបានផង ដោយគ្រាន់តែចាប់មេត្រីពូជចេញ ដើម្បីចិញ្ចឹមបំប៉នកូនត្រី គេគួរប្រើចំណីរបស់ត្រីក្រឹមខ្នាតតូចសម្រាប់ឲ្យកូនត្រីទីឡាព្យាស៊ី ព្រោះវាជាវិធីមួយងាយស្រួលជាងគេ។

កូនត្រីដែលត្រូវបានចិញ្ចឹមបំប៉ននោះ អាចធំលូតលាស់លឿនទៅបាន អាស្រ័យដោយកត្តាសីតណ្ហភាព ចំណី និងការថែទាំវា តែកត្តាសីតណ្ហភាពទឹកអាចសំខាន់ជាងគេ។

ត្រីទីឡាព្យា ជាប្រភេទត្រីម្យ៉ាងដែលរសជាតិរបស់វាអាស្រ័យទៅលើការកែច្នៃ តែចំពោះសាច់របស់វាផ្ទាល់ គឺគ្មានរស់ជាតិទេ វាមិនមានរសជាតិឆ្ងាញ់ដូចជាត្រីរបស់ស្រុកយើងឡើយ តែវាជាប្រភេទត្រីដែលអាចសម្របខ្លួនទៅក្នុងស្ថានភាពរបស់ទឹកបានច្រើនយ៉ាង និងមិនសូវមានជម្ងឺវាតត្បាតវាទេ៕

(ដកស្រង់ចេញពី ខេមបូឌាអេចប្រេសញូស៍)